| ៤-វរសេនីយ៍ទោ | សេក សេខ | អត្តលេខ ០០១៤៤១ | លេខាឯកឧត្តម ចាយ សាំងយុន រដ្ឋលេខាធិការ ក្រសួងការពារជាតិ |

៥-វរសេនីយ៍ទោ ឡឿន ឡឿត អត្តលេខ ០០១៧២១ នាយការិយាល័យផែនការ នាយកដ្ឋានវិស្វកម្ម

៦-វរសេនីយ៍ទោ អ៊ុន ប៉ូលី អត្តលេខ ០០១៧២៣ នាយការិយាល័យសំណង់អាគារ នាយកដ្ឋានវិស្វកម្ម

៧-វរសេនីយ៍ទោ ប៉ុស សាគុណ អត្តលេខ ០០១៧៥៨ នាយការិយាល័យបច្ចេកទេស នាយកដ្ឋានវិស្វកម្ម

៨-វរសេនីយ៍ទោ ពេជ្រ ចាន់មុន្នី អត្តលេខ ០០១៥៤១ នាយលេខាធិការដ្ឋាន នាយកដ្ឋានហិរញ្ញវត្ថុ

៩-វរសេនីយ៍ទោ ព្រុំ សត្ថារដ្ឋ អត្តលេខ ០០១៧៧៣ នាយការិយាល័យបច្ចេកទេស នាយកដ្ឋានសុខាភិបាល

១០-វរសេនីយ៍ទោ ស៊ី តេត់តី អត្តលេខ ០០១១៥៨ បច្ចុប្បន្នជា នាយករង នាយកដ្ឋានវិស្វកម្ម

១១-វរសេនីយ៍ទោ ធូច សុខណ្ឌរិទ្ធ អត្តលេខ ០១៧៣៧៤ នាយការិយាល័យភ័ស្តុភារហិរញ្ញវត្ថុ អគ្គនាយកដ្ឋានយោធសេវា

១២-វរសេនីយ៍ទោ តែខ សារុណ អត្តលេខ ០០១៦៩០ នាយលេខាធិការដ្ឋាន អគ្គនាយកដ្ឋានយោធសេវា

១៣-វរសេនីយ៍ទោ យ៉ាំង ចោមដេវី អត្តលេខ ០០១៦៨៤ នាយការិយាល័យសោតទស្សន៍បោះពុម្ពផ្សាយ អគ្គនាយកដ្ឋានយោធសេវា

១៤-វរសេនីយ៍ទោ គីម សុខណ្ណ អត្តលេខ ០០១៤៧៣ នាយលេខាធិការដ្ឋាន បច្ចុប្បន្នជា នាយករង នាយកដ្ឋានកិច្ចការយោធាស៊ីវិល

១៥-វរសេនីយ៍ទោ អៀត សុតិ អត្តលេខ ០០១៣៨៧ នាយលេខាធិការដ្ឋាន នាយកដ្ឋាននយោបាយផែនការ

១៦-វរសេនីយ៍ទោ ស៊ំ សុផាត អត្តលេខ ០០១៣៨៨ នាយការិយាល័យសេវាសង្គម នាយកដ្ឋាននយោបាយផែនការ

១៧-វរសេនីយ៍ទោ ម៉ីន ណារិទ្ធសម្បត្តិ អត្តលេខ ០០១៣៨៤ នាយការិយាល័យអាំងហ្វូម៉ាទិក នាយកដ្ឋាននយោបាយផែនការ

១៨-វរសេនីយ៍ទោ ខែត យូសីផល អត្តលេខ ០០១៩៤៤ នាយភ័ស្តុភារហិរញ្ញវត្ថុ អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស

១៩-វរសេនីយ៍ទោ មួច សារឿន អត្តលេខ ០០១៩៨៧ នាយលេខាធិការដ្ឋាន អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស

| | | | | |
|---|---|---|---|---|
| ២០-វរសេនីយ៍ទោ | ខាន់ | ប៊ុនធឿន | អត្តលេខ ០០១៩៦៧ | នាយការិយាល័យសព្វាវុធ នាយកដ្ឋានបច្ចេកទេស |
| ២១-វរសេនីយ៍ទោ | ខៀវ | ចណ្ឌារិទ្ធ | អត្តលេខ ០០៧២៤៩ | នាយករងសាលាជំនាញឯកទេសចំរុះ |
| ២២-វរសេនីយ៍ទោ | នង | ថាស់ | អត្តលេខ ០០១៩៥៦ | នាយការិយាល័យផែនការ នាយកដ្ឋានបច្ចេកទេស |
| ២៣-វរសេនីយ៍ទោ | ឆាង | ទូធី | អត្តលេខ ០១០៩២៩ | នាយការិយាល័យរថយន្តម៉ាស៊ីន នាយកដ្ឋានបច្ចេកទេស |
| ២៤-វរសេនីយ៍ទោ | ប៊ុន | អៀវីស | អត្តលេខ ០០១៩៤៩ | នាយការិយាល័យរថក្រោះរថពាសដែក នាយកដ្ឋានបច្ចេកទេស |
| ២៥-វរសេនីយ៍ទោ | ហង្ស | ប៊ុនឡេង | អត្តលេខ ០១៣៩០៨ | នាយអង្គភាពឃ្លាំសព្វាវុធ ក។៥ នាយកដ្ឋានបច្ចេកទេស |
| ២៦-វរសេនីយ៍ទោ | ទឹម | សំអុន | អត្តលេខ ០០៩៩៩៥ | នាយលេខាធិការដ្ឋាន នាយកដ្ឋានបំពាក់សំភារៈសឹក |
| ២៧-វរសេនីយ៍ទោ | ញ៉ៀប | ចិន្តាសត្ថិ | អត្តលេខ ០១៩៩៤២ | នាយការិយាល័យគ្រុបខ័ណ្ឌបំពាក់ នាយកដ្ឋានបំពាក់សំភារៈសឹក |
| ២៨-វរសេនីយ៍ទោ | អ៊ិន | សយ | អត្តលេខ ០១៧២៣៤ | នាយការិយាល័យគ្រប់គ្រងប្រគពជំនួយ នាយកដ្ឋានបំពាក់សំភារៈសឹក |
| ២៩-វរសេនីយ៍ទោ | ខៀប | ផាន់ណា | អត្តលេខ ០០២១៩៩ | នាយការិយាល័យគ្រប់គ្រងនិងបណ្តុះបណ្តាលជំនាញឯកទេស នាយកដ្ឋានបំពាក់សំភារៈសឹក |
| ៣០-វរសេនីយ៍ទោ | ម៉ែន | នៅ | អត្តលេខ ០០៨៤៣០ | នាយអង្គភាពឃ្លាំង ក។៨៦ នាយកដ្ឋានបច្ចេកទេស |
| ៣១-វរសេនីយ៍ទោ | អ៊ុក | ហួច | អត្តលេខ ០០១៦៦៣ | នាយលេខាធិការដ្ឋាន នាយកដ្ឋានបញ្ជូនសារ |
| ៣២-វរសេនីយ៍ទោ | បេង | សុត្ថារិទ្ធ | អត្តលេខ ០០៣៦៩៤ | នាយការិយាល័យផែនការ នាយកដ្ឋានបញ្ជូនសារ |
| ៣៣-វរសេនីយ៍ទោ | ហឿង | គួចច័ន្ទតារ៉ា | អត្តលេខ ០០១៦៧៣ | នាយការិយាល័យបច្ចេកទេស នាយកដ្ឋានបញ្ជូនសារ |
| ៣៤-វរសេនីយ៍ទោ | គាត់ | សុភាព | អត្តលេខ ០០១៩៦០ | នាយការិយាល័យសំភារៈ នាយកដ្ឋានបច្ចេកទេស |
| ៣៥-វរសេនីយ៍ទោ | សុខ | ខេមរដ្ឋ | អត្តលេខ ០០៣៨៣៦ | នាយបុគ្គលិក វិទ្យាស្ថានយោធាកម្ពុជា |

៣៦-វរសេនីយ៍ទោ គីម ចណ្ណសារ៉ុម អត្តលេខ ០០២២៤០ នាយករង មជ្ឈមណ្ឌលហ្វឹកហ្វឺន បញ្ជាការ-សេនាធិការ វិទ្យាស្ថានយោធាកម្ពុជា

៣៧-វរសេនីយ៍ទោ តាយ យោហា អត្តលេខ ០០១៦៣៨ នាយការិយាល័យផែនការនាយកដ្ឋាន ទាក់ទងអន្តរជាតិ

៣៨-វរសេនីយ៍ទោ តើត ណារិទ្ធ អត្តលេខ ០០១៦៣៩ នាយលេខាធិការដ្ឋាន នាយកដ្ឋាន ទាក់ទងអន្តរជាតិ

៣៩-វរសេនីយ៍ទោ ខៀវ សាផាត អត្តលេខ ០០១៤០៣ នាយការិយាល័យបណ្តុះបណ្តាល នាយកដ្ឋានបុគ្គលិក

៤០-វរសេនីយ៍ទោ ឡេង សុផុន អត្តលេខ ០០១៤១១ នាយការិយាល័យគ្រប់គ្រងទាហានបំរុង នាយកដ្ឋានបុគ្គលិក

៤១-វរសេនីយ៍ទោ ឈឹម ថាវី អត្តលេខ ០០១៤១០ នាយការិយាល័យគ្រប់គ្រងបុគ្គលិក ស៊ីវិល នាយកដ្ឋានបុគ្គលិក

៤២-វរសេនីយ៍ទោ ឈឹម សុផាន់ អត្តលេខ ០០១៤២០ នាយការិយាល័យគ្រប់គ្រងឯកសារ នាយកដ្ឋានបុគ្គលិក

៤៣-វរសេនីយ៍ទោ ថោង ចាន់សនា អត្តលេខ ០០១៤២៤ នាយការិយាល័យគ្រប់គ្រងអត្តសញ្ញាណប័ណ្ណ នាយកដ្ឋានបុគ្គលិក

៤៤-វរសេនីយ៍ទោ ធន សុខេង អត្តលេខ ០០១៤០៦ នាយលេខាធិការដ្ឋាន នាយកដ្ឋាន បុគ្គលិក

៤៥-វរសេនីយ៍ទោ សុខ ប៊ុនធឿន អត្តលេខ ០០១៤០៧ នាយការិយាល័យអាំងហ្វូម៉ាទិក នាយកដ្ឋានបុគ្គលិក

៤៦-វរសេនីយ៍ទោ ហ៊ឹម ណារិន អត្តលេខ ០០៤៥២៤ មេបញ្ជាការរង ទទួលបន្ទុកប្រតិបត្តិការនិងហ្វឹកហ្វឺន កងហោះដឹកជញ្ជូនគណៈប្រតិភូជាន់ខ្ពស់

៤៧-វរសេនីយ៍ទោ គីម សាឃួន អត្តលេខ ០០៤៥២៥ នាយផ្នែកយន្តហោះស្លាប កងហោះ ដឹកជញ្ជូនគណៈប្រតិភូជាន់ខ្ពស់

៤៨-វរសេនីយ៍ទោ ញ៉ឹក សម័យ អត្តលេខ ០០៣២៤៤ នាយករង ទីចាត់ការបំភ័ន្តអក្ខរៈ អគ្គបញ្ជាការដ្ឋាន

៤៩-វរសេនីយ៍ទោ ឃុត ស៊ុនហេង អត្តលេខ ០០២១៩៨ នាយករង ទីចាត់ការបច្ចេកទេស អគ្គបញ្ជាការដ្ឋាន

៥០-វរសេនីយ៍ទោ ឈុន គេង អត្តលេខ ០០២២០៤ នាយករង ទីចាត់ការហិរញ្ញវត្ថុ អគ្គបញ្ជាការដ្ឋាន

| | | | | |
|---|---|---|---|---|
| ៥១-វរសេនីយ៍ទោ | មាស | ដាន់យ៉េន | អត្តលេខ ០០២២០៥ | នាយករង ទីចាត់ការហិរញ្ញវត្ថុ អគ្គបញ្ជាការដ្ឋាន |
| ៥២-វរសេនីយ៍ទោ | គឹម | ហួត | អត្តលេខ ០០២២៧៥ | មេបញ្ជាការរង បញ្ជាការដ្ឋានបញ្ជូនសារ អគ្គបញ្ជាការដ្ឋាន |
| ៥៣-វរសេនីយ៍ទោ | គឹម | មឿន | អត្តលេខ ០០២២៧៤ | មេបញ្ជាការរង បញ្ជាការដ្ឋានបញ្ជូនសារ អគ្គបញ្ជាការដ្ឋាន |
| ៥៤-វរសេនីយ៍ទោ | តឿត | ចេន | អត្តលេខ ០០២៩៦៩ | នាយលេខាធិការដ្ឋាន នាយកដ្ឋានស្រាវជ្រាវចារកិច្ច អគ្គបញ្ជាការដ្ឋាន |
| ៥៥-វរសេនីយ៍ទោ | ចាន់ | ធនវិទ្យា | អត្តលេខ ០០៣៤៥៦ | នាយការិយាល័យបុគ្គលិក ទីចាត់ការបុគ្គលិក អគ្គបញ្ជាការដ្ឋាន |
| ៥៦-វរសេនីយ៍ទោ | ហៃ | សារ៉ិន | អត្តលេខ ០០១៩៥៧ | នាយការិយាល័យផែនការ ទីចាត់ការចលនូបត្ថម្ភ អគ្គបញ្ជាការដ្ឋាន |
| ៥៧-វរសេនីយ៍ទោ | នង | មណី | អត្តលេខ ០០១៩៦៣ | នាយការិយាល័យយោធបរិក្ខារ ទីចាត់ការចលនូបត្ថម្ភ អគ្គបញ្ជាការដ្ឋាន |
| ៥៨-វរសេនីយ៍ទោ | យិន | សាធ | អត្តលេខ ០០១៩៧៦ | នាយការិយាល័យគ្រាប់រំសេវ ទីចាត់ការចលនូបត្ថម្ភ អគ្គបញ្ជាការដ្ឋាន |
| ៥៩-វរសេនីយ៍ទោ | ជា | សារ៉ាត់ | អត្តលេខ ០០២២១៩ | នាយការិយាល័យវិទ្យាសាស្ត្រយោធា ទីចាត់ការហ្វឹកហ្វឺនអគ្គបញ្ជាការដ្ឋាន |
| ៦០-វរសេនីយ៍ទោ | កែច | រដ្ឋា | អត្តលេខ ០០២២១៦ | នាយការិយាល័យហ្វឹកហ្វឺនសាលា ទីចាត់ការហ្វឹកហ្វឺនអគ្គបញ្ជាការដ្ឋាន |
| ៦១-វរសេនីយ៍ទោ | អ៊ុន | ស៊ីផូ | អត្តលេខ ០០២០០១ | នាយការិយាល័យអប់រំចិត្តសាស្ត្រ ទីចាត់ការឃោសនាពត៌មាន អគ្គបញ្ជាការដ្ឋាន |
| ៦២-វរសេនីយ៍ទោ | ប៊ុន | ច័ន្ទមានិត | អត្តលេខ ០០៨៦៥៥ | នាយការិយាល័យព្រឹត្តប័ត្រពត៌មាន ទីចាត់ការឃោសនាពត៌មាន អគ្គបញ្ជាការដ្ឋាន |
| ៦៣-វរសេនីយ៍ទោ | ម៉ៅ | ស៊ីវ៉ាត | អត្តលេខ ០០២៦៥៨ | នាយការិយាល័យផ្តល់ពត៌មានយោធា សេនាធិការដ្ឋានអន្តរាគមន៍ |
| ៦៤-វរសេនីយ៍ទោ | អ៊ុក | សារុន | អត្តលេខ ០០២១៦៥ | នាយការិយាល័យទំពជីនាញ សេនាធិការដ្ឋានអន្តរាគមន៍ |
| ៦៥-វរសេនីយ៍ទោ | លាង | ដាន់ថា | អត្តលេខ ០០៣៨៧៨ | នាយការិយាល័យឃោសនាពត៌មាន សេនាធិការដ្ឋានអន្តរាគមន៍ |

| | | | | |
|---|---|---|---|---|
| ៦៦-វរសេនីយ៍ទោ | គុយ | ស៊ីវុត្ថី | អត្តលេខ ០០២១០៨ | មេបញ្ជាការរង និងជានាយសេនាធិការ បញ្ជាការដ្ឋានរថក្រោះ កងទ័ពជើងគោក |
| ៦៧-វរសេនីយ៍ទោ | សួខ | គុសល | អត្តលេខ ០០០៨១៣ | នាយសេនាធិការរង កងពលតូចអន្តរាគមន៍លេខ១២ បច្ចុប្បន្នជា មេបញ្ជាការរង កងពលតូចអន្តរាគមន៍លេខ១២ |
| ៦៨-វរសេនីយ៍ទោ | លី | សុវរិទ្ធិ | អត្តលេខ ០០១១៥៤ | នាយក សាលាពលទាហានទី ១ |
| ៦៩-វរសេនីយ៍ទោ | ជ៉ុខ | វិទ្ធីជ័យ | អត្តលេខ ០០០៩០០ | នាយក សាលាពលទាហានទី ២ |
| ៧០-វរសេនីយ៍ទោ | ឌុន | ឈាម | អត្តលេខ ០០២៨១២ | នាយក សាលាពលទាហានទី ៣ |
| ៧១-វរសេនីយ៍ទោ | គីម | ហួរ | អត្តលេខ ០០០៩៦៨ | នាយក សាលាពលទាហានទី ៤ |
| ៧២-វរសេនីយ៍ទោ | នួន | ទារី | អត្តលេខ ០០១០៤៩ | នាយក សាលាពលទាហានទី ៥ |
| ៧៣-វរសេនីយ៍ទោ | អេន | ណារ៉ាន់ | អត្តលេខ ០០៣១៤៩ | នាយក សាលាពលទាហាន យោធភូមិភាគពិសេស |
| ៧៤-វរសេនីយ៍ទោ | ចាស | ហេង | អត្តលេខ ០០២៦៧៨ | នាយការិយាល័យទី៣ យោធភូមិទី១ បច្ចុប្បន្នជា នាយសេនាធិការរង យោធភូមិភាគទី១ |
| ៧៥-វរសេនីយ៍ទោ | គន់ | ឌិន | អត្តលេខ ០០០៨៨៣ | មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងរតនគិរី បច្ចុប្បន្នជា នាយសេនាធិការរង យោធភូមិភាគទី១ |
| ៧៦-វរសេនីយ៍ទោ | ញ៉ឹម | សុវណ្ណ | អត្តលេខ ០០៣៣៩៨ | នាយការិយាល័យទី១ បញ្ជាការដ្ឋានកងទ័ពជើងអាកាស |
| ៧៧-វរសេនីយ៍ទោ | ប្រាក់ | សុម៉ាលី | អត្តលេខ ០០២៤៣០ | នាយការិយាល័យហិរញ្ញវត្ថុ បញ្ជាការដ្ឋានកងទ័ពជើងអាកាស |
| ៧៨-វរសេនីយ៍ទោ | ភឿង | ធុទ្ធី | អត្តលេខ ០០២៣៩៦ | នាយទាហានការពារផ្ទាល់ |
| ៧៩-វរសេនីយ៍ទោ | ពិត | ស៊ីថា | អត្តលេខ ០០៣៣៣១ | នាយទាហានការពារផ្ទាល់ |
| ៨០-វរសេនីយ៍ទោ | ឌុន | សុខុន | អត្តលេខ ០០២៣២៧ | នាយទាហានការពារផ្ទាល់ |
| ៨១-វរសេនីយ៍ទោ | លឹម | សុធា | អត្តលេខ ០០៣៣២៥ | នាយទាហានការពារផ្ទាល់ |
| ៨២-វរសេនីយ៍ទោ | នួច | សាវ៉ិន | អត្តលេខ ០០៣៧៧៦ | នាយទាហានការពារផ្ទាល់ |
| ៨៣-វរសេនីយ៍ទោ | ហែល | ហាន | អត្តលេខ ០០២៣៩៧ | នាយទាហានការពារផ្ទាល់ |
| ៨៤-វរសេនីយ៍ទោ | សួស | ស៊ីណា | អត្តលេខ ០០២៥៩៧ | នាយទាហានការពារផ្ទាល់ |

ខ- ការឡើងឋានន្តរសក្តិថ្នាក់វរនាវីឯក

| | | | | |
|---|---|---|---|---|
| ១-វរនាវីទោ | គ្រួច | គីមថុន | អត្តលេខ ០០២៥២៨ | នាយការិយាល័យទី៣ បញ្ជាការដ្ឋានកងទ័ពជើងទឹក |
| ២-វរនាវីទោ | លឹម | ឆាយ | អត្តលេខ ០០២៥០៨ | នាយការិយាល័យទី៤ បញ្ជាការដ្ឋានកងទ័ពជើងទឹក |

៣-វរនាវីទោ ច្រឹត ម៉ុនធឿន អត្តលេខ ០០២៥១៣ នាយការិយាល័យហិរញ្ញវត្ថុ បញ្ជាការដ្ឋានកងទ័ពជើងទឹក

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥៧ សសរ

# សេចក្តីសំរេច

## ស្តីពី

## ការរៀបចំកិច្ចប្រជុំ នៃក្រុមពិគ្រោះយោបល់លើកទី ៦

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២០ / អនក្រ . បក / ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៧០ / អនក្រ . បក / ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១** : ប្រគល់ភារកិច្ចជូនឯកឧត្តម គាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអនុប្រធានទី ១ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការដឹកនាំ និងសំរបសំរួលការងារត្រៀមរៀបចំ សំរាប់កិច្ចប្រជុំនៃក្រុមពិគ្រោះយោបល់លើកទី ៦ ដែលនឹងប្រព្រឹត្តទៅក្នុងឆ្នាំ ២០០២ ខាងមុខនេះ ។

**ប្រការ ២** : ក្នុងក្របខ័ណ្ឌនៃការដឹកនាំ និងសំរបសំរួលការងាររៀបចំសំរាប់កិច្ចប្រជុំនេះ ឯកឧត្តម គាត ឈន់ ត្រូវសហការជាមួយថ្នាក់ដឹកនាំនៃបណ្តាក្រសួង និងស្ថាប័នទាំងអស់របស់រាជរដ្ឋាភិបាល និងមានសិទ្ធិអញ្ជើញមន្ត្រីជាន់ខ្ពស់ អោយចូលរួមប្រជុំអន្តរក្រសួង និងមានសិទ្ធិចាត់ចែង ពិគ្រោះយោបល់ជាមួយតំណាងប្រទេស និងអង្គការអន្តរជាតិអ្នកផ្តល់ជំនួយទ្វេភាគី និងពហុភាគី ដើម្បីសំរបសំរួលការងារ និងដើម្បីរៀបចំសេចក្តីព្រាងឯកសារចាំបាច់នានា ។

**ប្រការ ៣** : ឯកឧត្តម គាត ឈន់ ត្រូវរាយការណ៍ជាបន្តបន្ទាប់ជូននាយករដ្ឋមន្ត្រី អំពីលទ្ធផលនៃការងារដែលបានបំពេញ ហើយត្រូវរៀបចំឯកសារចាំបាច់នានា សំរាប់កិច្ចប្រជុំលើកទី ៦ នេះ ដើម្បីដាក់ជូននាយករដ្ឋមន្ត្រីពិនិត្យ ផ្តល់យោបល់ណែនាំ និងអនុម័ត មុននឹងយកទៅប្រើប្រាស់ជាផ្លូវការ ។

**ប្រការ ៤** : ក្នុងការបំពេញកិច្ចការនេះ ឯកឧត្តម គាត ឈន់ ប្រើប្រាស់វចនាសម្ព័ន្ធរបស់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា ( កអក / គជនា ) ដែលមានឯកឧត្តម ឈៀង យ៉ាណារ៉ា ជាអគ្គលេខាធិការសំរាប់ជំនួយការងារប្រចាំថ្ងៃ ។

**ប្រការ ៥** : សេចក្តីសំរេចនេះមានប្រសិទ្ធភាពរហូតដល់កិច្ចប្រជុំលើកទី ៦ នៃក្រុមពិគ្រោះយោបល់បានប្រព្រឹត្តទៅចប់សព្វគ្រប់ ។

**ប្រការ ៦** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងឯកឧត្តម គាត ឈន់ ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០១*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៦ " ដើម្បីអនុវត្ត "*
- *ឯកសារ- កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** : ៧៣ សសរ

# សេចក្តីសំរេច

## ស្តីពី

## ការតែងតាំង សមាជិក-សមាជិកា នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

❁❁❁❁❁

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០២០១ / ០៣៦ ចុះថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ ២០០១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

## <u>សំរេច</u>

**ប្រការ១.-**

ត្រូវបានតែងតាំងជាសមាជិកភាព នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី មានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១- លោកជំទាវ **មូរ សុខហួរ** | រដ្ឋមន្ត្រីក្រសួង កិច្ចការនារី និងអតីតយុទ្ធជន | ប្រធាន |
| ២- ឯកឧត្តម **ខូវ ម៉េងហ៊ាន** | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣- ឯកឧត្តម **ស៊ុយ នូ** | រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៤- លោកជំទាវ **យូ អយ** | រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន | សមាជិកា |
| ៥- ឯកឧត្តម **គង់ វិបុល** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

៦- លោកជំទាវ ប្រាក់ ចន្ថា រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា សមាជិកា

៧- លោកជំទាវ ស៊ិន ស៊ី អនុរលេខាធិការដ្ឋាន រាជរដ្ឋាភិបាល សមាជិកា

៨- ឯកឧត្តម ម៉ុក ឋន រដ្ឋលេខាធិការ ក្រសួង អប់រំ យុវជន និងកីឡា សមាជិក

៩- ឯកឧត្តម យឹម ឆៃលី រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

១០- អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ ឥន្ទវង្សព៍ស៊ីវុឌ្ឍ រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

១១- ឯកឧត្តម អ៊ឹង គីវុន រដ្ឋលេខាធិការ ក្រសួងសុខាភិបាល សមាជិក

១២- ឯកឧត្តម ឧុត និនះជឿន រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ សមាជិក

១៣- ឯកឧត្តម អ៊ី ដារាវុធ រដ្ឋលេខាធិការ ក្រសួងពត៌មាន សមាជិក

១៤- ឯកឧត្តម អ៊ូ ឱរាត រដ្ឋលេខាធិការ ក្រសួងផែនការ សមាជិក

១៥- ឯកឧត្តម ចាន់ មិន អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា សមាជិក

១៦- លោកជំទាវ ស៊ុន សារឿន អនុរដ្ឋលេខាធិការ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិកា

១៧- លោកស្រី ចំនួ ហារ៉ានវត្តី អគ្គលេខាធិការក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សមាជិកា

**ប្រការ២.-**

សមាជិក-សមាជិកា នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីនេះ មានភារកិច្ច អនុវត្តការងារ ទៅតាមការតំរង់ទិស នៃព្រះរាជក្រឹត្យលេខ នស / រកត / ០២០១ / ០៨៦ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងត្រូវអញ្ជើញចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី-រដ្ឋលេខាធិការ-ក្រសួងស្ថាប័នពាក់ព័ន្ធ ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជានិងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលអនុវត្ត តាមសេចក្តីសំរេចនេះអោយមានប្រសិទ្ធិភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

រាជធានីភ្នំពេញថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ១ និង ប្រការ៣
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ...៥៧៤... ស.សរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតក្រុមការងារដើម្បីសិក្សារកដំណោះស្រាយលើដី ផ្ទះ អតីតស្ថានទូតជប៉ុនប្រចាំនៅទីក្រុងភ្នំពេញ

...

**រាជរដ្ឋាភិបាល**

...

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-យោងតាមសេចក្តីត្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

**ប្រការ១.-** ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួងមួយ ដើម្បីសិក្សារកដំណោះស្រាយលើ ដី ផ្ទះអតីតស្ថានទូត នៃប្រទេសជប៉ុននៅភ្នំពេញ មុនឆ្នាំ១៩៧៥ ដែលមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១-លោកជំទាវ | **ស៊ិន ស៊ី** អគ្គលេខាធិការរងរាជរដ្ឋាភិបាល | ប្រធាន |
| ២-ឯកឧត្តម | **ហោ សុធន** តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៣-លោក | **តាំង លាងខ័ណ្ឌ** តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤-លោក | **ឌុល គឿន** តំណាងក្រសួងក្រសួងមហាផ្ទៃ | សមាជិក |
| ៥-លោក | **លឹម សំកុល** ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |

៦-លោក **សុខ លក្ខិណា** នាយករងខុទ្ទកាល័យ សាលាក្រុងភ្នំពេញ សមាជិក

**ប្រការ២.**- ក្រុមការងារនេះមានភារកិច្ចដូចតទៅ :

-សិក្សារកដំណោះស្រាយលើការទាមទារយកវិញរបស់រាជរដ្ឋាភិបាលជប៉ុន នូវដី ផ្ទះអតីតស្ថានទូតទាំង២ ដែលក្នុងនោះមានផ្ទះឯកឧត្តម **ហ៊ឹម ឆែម** និងអាគារការិយាល័យ លិខិតឆ្លងដែនរបស់ក្រសួងមហាផ្ទៃ

-សិក្សាវាយតំលៃលើដី និងសំណង់ផ្ទះ របស់ឯកឧត្តម **ហ៊ឹម ឆែម** និងអាគារការិយាល័យលិខិតឆ្លងដែនរបស់ក្រសួងមហាផ្ទៃ លើតំលៃដែលត្រូវទូទាត់ ដោយពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសំរុះសំរួលជាមួយនិងម្ចាស់កម្មសិទ្ធិ

-ធ្វើការស្ទាបស្ទង់ជាមួយភាគីជប៉ុនអំពីដំណោះស្រាយផ្សេងៗដែលអាចធ្វើការសំរុះសំរួលលើគ្រប់ទិដ្ឋភាព ។

**ប្រការ៣.**- ក្រុមការងារនេះអាចស្នើកិច្ចសហការពីគណៈកម្មការវាយតំលៃ របស់គណៈកម្មាធិការឯកជនភាវូនីយកម្ម និងត្រូវធ្វើរបាយការណ៍ ពីលទ្ធផលនៃការចរចាជាមួយភាគីជប៉ុន និងលើកគំរោងចំណាយ ជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យ និងសំរេច ។

**ប្រការ៤.**-សមាជិកក្រុមការងារត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន និងត្រូវរំសាយជាស្វ័យប្រវត្តិ បន្ទាប់ពីចប់ភារកិច្ច ។

**ប្រការ៥.**- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអភិបាលរាជធានីភ្នំពេញ និងសាមីជនដែលមានឈ្មោះចែងក្នុងប្រការ១ ត្រូវទទួលអនុវត្តតាមសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០០១*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចប្រការ១ និង ប្រការ៥
-កាលប្បវត្តិ-ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៣ ស.ន.ណ.ន

## សារាចរណែនាំ

## ស្តីពី

## ការថែរក្សា រៀបចំទុកដាក់អដ្ឋិធាតុប្រជាជនរងគ្រោះ ដោយអំពើប្រល័យពូជសាសន៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៨) និងការរៀបចំតំបន់អន្លង់វែងឱ្យទៅជាតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រ

ក្រោយថ្ងៃរំដោះ ៧មករា ឆ្នាំ ១៩៧៩ភ្លាម ទឹកដីកម្ពុជាទាំងមូល មានរណ្តៅសាកសពរួមជាច្រើនកន្លែង ដែលរបបប្រល័យពូជសាសន៍ ប៉ុល ពត បានបន្សល់ទុកជាវត្ថុតាងនៃឧក្រិដ្ឋកម្មមកលើប្រជាជនស្លូតត្រង់ ។ ភ្លាមនោះ អាជ្ញាធរ និងប្រជាពលរដ្ឋ បានខិតខំយកអដ្ឋិធាតុរបស់ជនរងគ្រោះ មកថែរក្សាតំកល់ទុកបានគត់មត់ល្អ កន្លែងខ្លះបានធ្វើស្តូប និងបានធ្វើកន្លែងតំកល់ទុកដាក់ជាបូជនីយដ្ឋានបានសមរម្យ ។ ប៉ុន្តែ រហូតមកដល់ពេលនេះ រាជរដ្ឋាភិបាល បានសង្កេតឃើញថា នៅកន្លែងដែលបានតំកល់ទុកអដ្ឋិធាតុពីមុន ពុំទាន់បានយកចិត្តទុកដាក់ថែរក្សាឱ្យបានល្អជាប្រចាំនៅឡើយ ។

ដើម្បីថែរក្សាទុកអដ្ឋិធាតុជាភស្តុតាងនៃឧក្រិដ្ឋកម្មប្រវត្តិសាស្ត្រ សំរាប់ជាមូលដ្ឋានរំលឹកអប់រំដល់ប្រជាពលរដ្ឋកម្ពុជាទាំងមូល ពិសេសដល់វ័យជំនាន់ក្រោយ ឱ្យចងចាំជានិច្ចនូវប្រវត្តិសាស្ត្រដ៏ឈឺចាប់ខ្លោចផ្សា និងជូរចត់បំផុត ដែលរបបកម្ពុជាប្រជាធិបតេយ្យ បានប្រព្រឹត្តមកលើប្រជាជន និងទឹកដីមាតុភូមិកម្ពុជា កាលពីឆ្នាំ ១៩៧៥-១៩៧៨ អស់រយៈកាល ៣ឆ្នាំ ៨ខែ និង ២០ថ្ងៃនេះ ជាពិសេស ការរៀបចំថែរក្សាតំបន់អន្លង់វែងសំរាប់ធ្វើជាសារមន្ទីរប្រវត្តិសាស្ត្រជូនដល់ភ្ញៀវទេសចរជាតិ និងអន្តរជាតិនា ពេលអនាគត រាជរដ្ឋាភិបាល សូមធ្វើការណែនាំដូចតទៅ :

១- អាជ្ញាធរដែនដី ខេត្ត-ក្រុង ទាំងអស់ សហការជាមួយមន្ទីរជំនាញពាក់ព័ន្ធនៅជុំវិញ ខេត្ត-ក្រុង ត្រូវពិនិត្យជួសជុល និងថែរក្សាឡើងវិញ ឱ្យបានល្អនូវកន្លែងតំកល់អដ្ឋិធាតុទាំងឡាយដែលបានធ្វើកន្លងមក ហើយត្រូវពិនិត្យស្រាវជ្រាវនូវរណ្តៅដែលនៅសេសសល់ ដើម្បីរៀបចំកន្លែងទាំងអស់នេះ ឱ្យទៅជាបូជនីយដ្ឋានដែលមានរបងហ៊ុំព័ទ្ធ មានដាំដើមឈើ និងដាក់ផ្លាកសញ្ញាពតិមានប្រវត្តិសាស្ត្រឱ្យបានល្អ ដើម្បីបង្ហាញជូនដល់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរ ។

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងទេសចរណ៍ត្រូវធ្វើការណែនាំបន្ថែមអំពីផ្នែកបច្ចេកទេស ហើយត្រូវចាត់តាំងមន្ត្រីជំនាញក្រោមឱវាទ ឱ្យចុះសហការជាមួយអាជ្ញាធរដែនដី ក្នុងកិច្ចការនេះ ។

២- ដោយឡែកនៅតំបន់អន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ដែលជាតំបន់ប្រវត្តិសាស្ត្រនៃជីវិតនយោបាយចុងក្រោយរបស់មេដឹកនាំ និងអង្គការចាត់តាំងខាងយោធារបស់ខ្មែរក្រហម ប៉ុល ពត ក្រសួងទេសចរណ៍ត្រូវខិតខំបន្តអនុវត្តដូចដែលរាជរដ្ឋាភិបាល បានណែនាំកន្លងមក ដោយត្រូវសហការជាមួយអាជ្ញាធរដែនដី ក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ ជាពិសេសក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ យោធភូមិភាគទី ៤ មជ្ឈមណ្ឌលកំចាត់មីនកម្ពុជា **(CMAC)** និងមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីធ្វើការបោសសំអាតមីន រៀបចំប្លង់មេឱ្យបានត្រឹមត្រូវស្រាវជ្រាវឯកសាររៀបចំជាសារៈមន្ទីរប្រវត្តិសាស្ត្រ ដោយខិតខំស្វែងរកគ្រប់ប្រភពថវិកាជំនួយ ដើម្បីធ្វើការរៀបចំថែរក្សានូវវត្ថុតាងប្រវត្តិសាស្ត្រទាំងអស់ និងសំរាប់កសាង រៀបចំតំបន់នោះ ឱ្យក្លាយទៅជាតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រមួយរបស់ប្រទេសជាតិ ។

ហាមឃាត់ដាច់ខាតនូវការរំលោភយកដីធ្លី និងការបែងចែកដីធ្លីបែបអនាធិបតេយ្យ ឬការសាងសង់សំណង់ណាមួយ នៅតំបន់អន្លង់វែង ដែលធ្វើឱ្យមានការប៉ះពាល់ដល់តំបន់ប្រវត្តិសាស្ត្រនេះ ដោយគ្មានការអនុញ្ញាតពីរាជរដ្ឋាភិបាល លើកលែងតែការសាងសង់លំនៅដ្ឋានរបស់ប្រជាពលរដ្ឋនៅក្នុងភូមិ ឃុំនោះ ដែលត្រូវបានអនុញ្ញាតស្របតាមការកំណត់ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

៣- ត្រូវយកចិត្តទុកដាក់ខិតខំអនុវត្តកិច្ចការទាំងអស់ខាងលើ ឱ្យបានមុនថ្ងៃ ៧មករា ឆ្នាំ ២០០២នេះ ដែលជាខួបលើកទី ២៣ នៃថ្ងៃផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០១

ហ៊ុន សែន

**ចំលងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- សាលាខេត្ត-ក្រុង
- កាលប្បវត្តិ-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
*Nation - Religion - King*

រាជរដ្ឋាភិបាល
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
Council for the Development of Cambodia

លេខ ៣៦៧៣/០១ ក.អ.ក

រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែ ធ្នូ ឆ្នាំ២០០១

# ប្រកាស

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ អនុក្រឹត្យលេខ ៧០ អនក្រ/បក ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញ អនុក្រឹត្យលេខ ១០៨ អនក្រ/បក ចុះថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបន្ថែមសមាជិករបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងតាមសំណើរបស់ឯកឧត្តមអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងតំរូវការចាំបាច់នៃការងារ

## សំរេច

**ប្រការ១:** តែងតាំងលោក ខេត សរី ជាអនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងរដ្ឋបាល អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

<u>ប្រការ២</u>: អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍ អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា នាយកខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងសាមីខ្លួនត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

គាត ឈន់

<u>កន្លែងទទួល</u>:

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-ដូចប្រការ២ "ដើម្បីអនុវត្ត"

-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MOSALVY

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ : ៣២៨ សកបយ.

រាជធានីភ្នំពេញ. ថ្ងៃទី១៣ ខែ ធ្នូ ឆ្នាំ២០០១

## ប្រកាស
## ស្តីពី
## ការតែងតាំងសមាជិកនៃគណៈកម្មការប្រឹក្សាការងារ

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការកែសំរួលអនុក្រឹត្យលេខ ២៩ អនក្រ.បក ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៩៨ និងអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីសមាសភាព និងការប្រព្រឹត្តទៅនៃគណៈកម្មការប្រឹក្សាការងារ ។

## សំរេច

**ប្រការ១.-** តែងតាំងសមាជិកពេញសិទ្ធិនៃគណៈកម្មការប្រឹក្សាការងារ នៅអមក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដែលមានសមាសភាពដូចតទៅ :-

| | | |
|---|---|---|
| ១-ឯកឧត្តម អ៊ិត សំហេង | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា | ជាប្រធាន |
| ២-លោក លីវ ប៊ុនហៃ | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៣-លោក ឱក តារារិទ្ធ | តំណាងក្រសួងពាណិជ្ជកម្ម | ជាសមាជិក |
| ៤-លោក គីម ទូច | តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ជាសមាជិក |
| ៥-លោកស្រី វេជ្ជ.ប្រាក់ ពិសិដ្ឋវង្សី | តំណាងក្រសួងសុខាភិបាល | ជាសមាជិក |
| ៦-លោក ស៊ឹម បាង្ស | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាសមាជិក |
| ៧-លោកជំទាវ កេត សំអាត | តំណាងក្រសួងកិច្ចការនារី និងអតីតយុទ្ធជន | ជាសមាជិក |
| ៨-លោក ឡុញ ហ៊ាល | តំណាងក្រសួងបរិស្ថាន | ជាសមាជិក |
| ៩-លោក នួន សុខផល | តំណាងក្រសួងសារធារណៈការ និងដឹកជញ្ជូន | ជាសមាជិក |
| ១០-លោក ឡុង ពៅប្រាជ្ញា | តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា | ជាសមាជិក |
| ១១-លោក ជួន មុំថុល | តំណាងសហព័ន្ធសហជីពខ្មែរ | ជាសមាជិក |
| ១២-លោក សោម អូន | តំណាងសហព័ន្ធសហជីពកម្មករកម្ពុជា | ជាសមាជិក |
| ១៣-លោក ជា វិជ្ជា | តំណាងសហជីពសេរីកម្មករ នៃព្រះរាជាណាចក្រកម្ពុជា | ជាសមាជិក |
| ១៤-លោក រស់ សុក | តំណាងសហព័ន្ធសហជីពឯករាជ្យកម្ពុជា | ជាសមាជិក |
| ១៥-អ្នកស្រី ម៉ម ញ៉ឹម | តំណាងសហព័ន្ធសហជីពជាតិ នៃឧស្សាហកម្មវាយនភ័ណ្ឌកាត់ដេរកម្ពុជា | ជាសមាជិក |
| ១៦-លោកប៉ាស្កាលប្រង់ហ្កញ៉ុង | តំណាងសហព័ន្ធពាណិជ្ជករ និង សមាគមពាណិជ្ជកម្មនៅកម្ពុជា | ជាសមាជិក |
| ១៧-លោក យ៉ាំ ស៊ុយសាំង | តំណាងសមាគមពាណិជ្ជកម្ម ហុងកុង ម៉ាកាវ ប្រទេសចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា | ជាសមាជិក |
| ១៨-លោក ហ៊ិនរី កុងឈីភីន | តំណាងសមាគមឧស្សាហកម្មឈើកម្ពុជា | ជាសមាជិក |
| ១៩-លោក វ៉ាន់ ស៊ូអៀង | តំណាងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា | ជាសមាជិក |
| ២០-លោក វ៉ាង ស៊ីន | តំណាងសមាគមឧស្សាហកម្មស្បែកជើងកម្ពុជា | ជាសមាជិក។ |

**ប្រការ២.-** តែងតាំងសមាជិកបំរុងនៃគណៈកម្មការប្រឹក្សាការងារដែលមានសមាសភាពដូចតទៅ :-

| | | |
|---|---|---|
| ១- លោក ម៉ា វឿន | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិកបំរុង |

| | | |
|---|---|---|
| ២-លោក មាន សុភា | តំណាងក្រសួងពាណិជ្ជកម្ម | ជាសមាជិកបំរុង |
| ៣-លោក កែវ សុវត្ថិ | តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ជាសមាជិកបំរុង |
| ៤-លោក វេជ្ជ.ថាច វ៉ារ៉ុន | តំណាងក្រសួងសុខាភិបាល | ជាសមាជិកបំរុង |
| ៥-លោក វ៉ៃ លឹម | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាសមាជិកបំរុង |
| ៦-លោកស្រី ឯក វីរៈ | តំណាងក្រសួងកិច្ចការនារី និងអតីតយុទ្ធជន | ជាសមាជិកបំរុង |
| ៧-លោក ទា ជុប | តំណាងក្រសួងបរិស្ថាន | ជាសមាជិកបំរុង |
| ៨-លោក មាស ម៉ូនីកា | តំណាងក្រសួងសាធារណៈការ និងដឹកជញ្ជូន | ជាសមាជិកបំរុង |
| ៩-លោក អន សូផាណារ៉ា | តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ជាសមាជិកបំរុង |
| ១០-លោក ចក់ យ៉ន | តំណាងសហព័ន្ធសហជីពខ្មែរ | ជាសមាជិកបំរុង |
| ១១-លោក លាង ស៊ុនហ៊ាង | តំណាងសហព័ន្ធសហជីពកម្មករកម្ពុជា | ជាសមាជិកបំរុង |
| ១២-លោក សយ សំអុន | តំណាងសហព័ន្ធសហជីពខ្មែរនៃកម្មករសំណង់ និងព្រៃឈើ | ជាសមាជិកបំរុង |
| ១៣-អ្នកស្រី ទេព គីមវណ្ណី | តំណាងសហព័ន្ធសហជីពឯករាជ្យកម្ពុជា | ជាសមាជិកបំរុង |
| ១៤-អ្នកស្រី កេន ឆេងឡាង | តំណាងសហព័ន្ធសហជីពជាតិនៃឧស្សាហកម្មវាយនភ័ណ្ឌកាត់ដេរកម្ពុជា | ជាសមាជិកបំរុង |
| ១៥-លោកស្រីឡោ ហ្សូហ្សែត | តំណាងសហព័ន្ធពាណិជ្ជករ និងសមាគមពាណិជ្ជកម្មនៅកម្ពុជា | ជាសមាជិកបំរុង |
| ១៦-លោក លី ហួត | តំណាងសមាគមពាណិជ្ជកម្ម ហុងកុង ម៉ាកាវ ប្រទេសចិនប្រចាំព្រះរាជាណាចក្រកម្ពុជា | ជាសមាជិកបំរុង |
| ១៧-លោកZhou Xiong Zhi | តំណាងសមាគមឧស្សាហកម្មឈើនៅកម្ពុជា | ជាសមាជិកបំរុង |
| ១៨-លោក គង់ សាង | តំណាងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា | ជាសមាជិកបំរុង |
| ១៩-លោក លីន យូហ៊ុន | តំណាងសមាគមឧស្សាហកម្មស្បែកជើងកម្ពុជា | ជាសមាជិកបំរុង ។ |

**ប្រការ៣.-** ក្នុងករណីដែលឯកឧត្តមរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អវត្តមាន ឬជាប់រវល់កិច្ចការមមាញឹក លោកអាចផ្ទេរសិទ្ធិជូនឯកឧត្តមរដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ឬឯកឧត្តមអគ្គនាយកការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ទទួលភារកិច្ចជាប្រធានស្តីទី នៃគណៈកម្មការប្រឹក្សាការងារ ។

**ប្រការ៤.-** គណៈកម្មការប្រឹក្សាការងារត្រូវរួមប្រជុំតាមការកំណត់ និងការអញ្ជើញរបស់ប្រធាន ។

**ប្រការ៥.-** ប្រកាសនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ចម្លងជូន**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី

-ទីស្ដីការគណៈរដ្ឋមន្ត្រី

-គ្រប់ក្រសួងពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

-អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

-អគ្គនាយកដ្ឋានការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ នៃក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

"ដើម្បីអនុវត្ត"

-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង

"ដើម្បីជ្រាប"

-រាជកិច្ច

-កាលប្បវត្តិ និងឯកសារ

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ: ៥៧៤៧...កសក

## សេចក្តីប្រកាស
## ស្តីពី
## ការផ្អាកសកម្មភាពអាជីវកម្មព្រៃគុបសំរាប់ក្រុមហ៊ុនព្រៃសម្បទាន

ក្នុងអាណត្តិទី ២ នៃ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ម៉ឺងម៉ាត់ និង ឈ្លាសវៃបំផុតរបស់សម្តេច នាយករដ្ឋមន្ត្រី **ហ៊ុន សែន** ដំណើរការនៃការកែទំរង់វិស័យព្រៃឈើបាននិងកំពុងទទួលនូវជោគជ័យជាបន្តបន្ទាប់ ជាពិសេសក្នុងការលុបបំបាត់អំពើអនាធិបតេយ្យព្រៃឈើគ្រប់ប្រភេទ ហើយបង្កើតបាននូវសណ្តាប់ធ្នាប់ និង ប្រក្រតីភាពជាមូលដ្ឋានលក្ខខណ្ឌគន្លឹះសំរាប់ឈានឆ្ពោះទៅរកការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព នៅកម្ពុជានាអនាគតឆាប់ៗខាងមុខនេះ។ ទន្ទឹមនេះ ដំណើរការកែទម្រង់ការគ្រប់គ្រងព្រៃសម្បទានក៏បាននិងកំពុងអនុវត្តយ៉ាងសកម្មដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រោមជំនួយបច្ចេកទេសពីធនាគារអភិវឌ្ឍន៍អាស៊ីបានដំណើរការ និង បញ្ចប់ការត្រួតពិនិត្យសើរើកិច្ចព្រមព្រៀងព្រៃសម្បទានកម្ពុជាទូទាំងប្រទេស ហើយជាលទ្ធផលគឺរាជរដ្ឋាភិបាលកម្ពុជាបានសំរេចលុបចោល និង ដកហូតព្រៃសម្បទានចំនួន ១៦ កន្លែង មានផ្ទៃដីសរុប ២.៤៣៧.៩៧០ ហិកតា ពី ១២ ក្រុមហ៊ុន។ រីឯក្រុមហ៊ុនព្រៃសម្បទានទាំង ១៧ ដែលនៅមានសុពលភាពបានឯកភាពធ្វើការសិក្សារៀបចំផែនការគ្រប់គ្រងព្រៃសម្បទានសារជាថ្មី និង ចរចាកិច្ចព្រមព្រៀងវិនិយោគទុនព្រៃសម្បទានសារជាថ្មីតាមគំរូបមាណិយ៍អន្តរជាតិនៃនិរន្តរភាពព្រៃឈើនៅត្រឹមដំណាច់ឆ្នាំ ២០០១ នេះ។ ប៉ុន្តែរហូតមកដល់បច្ចុប្បន្ននេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានពិនិត្យឃើញថាពុំទាន់មានក្រុមហ៊ុនព្រៃសម្បទានណាមួយ បានសំរេចលទ្ធផលទាំងស្រុងតាមកម្មវិធី ដែលបានឯកភាពគ្នាខាងលើនេះនៅឡើយ ។

អាស្រ័យហេតុនេះ ដើម្បីសំរេចឱ្យបាននូវគោលដៅជាចុងក្រោយក្នុងការបំពេញលក្ខខណ្ឌគន្លឹះសំរាប់ធានាដល់ការគ្រប់គ្រងព្រៃសម្បទានកម្ពុជាដោយនិរន្តរភាពនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ សំរេចធ្វើសេចក្តីប្រកាសជាសាធារណៈដូចខាងក្រោមនេះ :

១. ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០២ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ(នាយកដ្ឋានរុក្ខា-ប្រមាញ់) នឹងធ្វើការផ្អាកការផ្តល់លិខិតអនុញ្ញាតអោយធ្វើអាជីវកម្មព្រៃគុប ដល់ព្រៃសម្បទានិកទាំងអស់ រហូតដល់មានការយល់ព្រមលើផែនការគ្រប់គ្រងព្រៃឈើថ្មីច្បាស់លាស់ស្របទៅតាមតំរូវការនៃបទប្បញ្ញត្តិច្បាប់ និង បច្ចេកទេសសំរាប់ដំណើរការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ។

២. រាល់ព្រៃគុបដែលបាននិងកំពុងធ្វើអាជីវកម្មក្នុងឆ្នាំ ២០០១ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (នាយកដ្ឋានរុក្ខា-ប្រមាញ់)នឹងធ្វើការបិទព្រៃគុប ដោយបញ្ជាឱ្យព្រៃសម្បទានិកទាំងអស់ធ្វើការបញ្ឈប់រាល់សកម្មភាពអាជីវកម្មកាប់រំលំដើមឈើត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០១ នេះជាកំហិត រហូតដល់តំរូវការនៃបទប្បញ្ញត្តិច្បាប់ និង បច្ចេកទេសប្រតិបត្តិត្រូវបានបំពេញ ។

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី______ខែ______ឆ្នាំ_______

៣. នាយកដ្ឋានរុក្ខា-ប្រមាញ់ ត្រូវធ្វើសារពើភ័ណ្ឌឈើហ៊ុបស្របច្បាប់ ដែលបានមកពីការផ្ទេរអាជីវកម្មកាប់រំលំមុនថ្ងៃទី ០១ ខែមករា ឆ្នាំ២០០២ នៅក្នុងព្រៃគុប គំនរឈើ និង ទីកន្លែងផ្សេងៗទៀត ដែលស្ថិតនៅក្នុងតំបន់ព្រៃសម្បទាន ឬ ទីគំនរឈើផ្សេងៗទៀត ដើម្បីកំណត់ឱ្យបានច្បាស់លាស់នូវសន្និធិឈើហ៊ុបខាងលើសំរាប់រង់ចាំព្រៃសម្បទានិកបង់ថ្លៃសួយសារ និង ដឹកជញ្ជូនទៅកាន់កន្លែងកែច្នៃ ឬ ប្រើប្រាស់ ។ លទ្ធផលនៃសារពើភ័ណ្ឌឈើហ៊ុបទាំងអស់នេះ អាចនឹងផ្តល់ជូនតាមការស្នើសុំ ។

៤. ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០០២ នាយកដ្ឋានរុក្ខា-ប្រមាញ់ ត្រូវផ្អាកការផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនឈើហ៊ុបដល់ព្រៃសម្បទានិក រហូតដល់មានការបង់ថ្លៃសួយសារ និង វាយត្រារូច ។

៥. នាយកដ្ឋានរុក្ខា-ប្រមាញ់ ត្រូវរាយការណ៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទនូវលទ្ធផលការងារ ដែលអនុវត្តបាន និង ការលំបាកក្នុងការអនុវត្តន៍ ដើម្បីក្រសួងមានវិធានការជាក់ស្តែង ។

សេចក្តីប្រកាសនេះ មានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី 13 ខែ ធ្នូ ឆ្នាំ ២០០១

រដ្ឋមន្ត្រី

ចាន់-សារុន

**កន្លែងទទួល:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងពិតមាន
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងបរិស្ថាន
- ក្រសួងផែនការ
- ក្រសួងយុត្តិធម៌
- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- គ្រប់សាលាខេត្ត-ក្រុង

**"ដើម្បីជូនជ្រាប"**

- អង្គភាពក្រោមឱវាទក្រសួង
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទខេត្ត-ក្រុង
- សមាគមន៍ឧស្សាហកម្មឈើកម្ពុជា
- គ្រប់ក្រុមហ៊ុនព្រៃសម្បទាន

**"ដើម្បីអនុវត្ត"**